16/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៦៨
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣
សាលដីកា
លេខ : ១៤៥ "ង"
ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៤។

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

### ក្រឡាបញ្ជី

លោកស្រី [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**អ្នកស្រី [redacted]ុភា (ជាអ្នកទទួលសិទ្ធិពីឈ្មោះ [redacted]ង់ល្បី, [redacted] សុភាព [redacted]ហា, [redacted] សុជារី) "ចុងបណ្ដឹងសាទុក្ខ" អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិអូរអំបិល ឃុំអូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

៤៧១





4.41

Scanned with CamScanner

ចុងចម្លើយៈលោក [redacted]សារ៉ាយ ហៅ សម្បត្តិ (ជាអ្នកទទួលសិទ្ធិពីឈ្មោះ [redacted] សុខា, [redacted]ជំនោរ, [redacted] ចំណាប់, [redacted]វតនា, [redacted] រតនៈ, [redacted] ធីតា, [redacted] ម៉ូនីកា, [redacted] ហ៊ីម) "ម្ចាស់បណ្ដឹងសាទុក្ខ" អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

មេធាវី : លោក [redacted] តំណាងដោយអាណត្តិ

<u>អំពីវិវាទ</u> :-ប្ដឹងទាមទារបែងចែកមរតក

## <u>អំពីអង្គហេតុ និង ចំណុចវិវាទៈ</u>

### ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:</u>

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១០ របស់ដើមចោទឈ្មោះ [redacted] ផល្លា និង អ៊ីវ សុភា បញ្ជាក់ថា : សពឈ្មោះ [redacted]ហួរ មានប្រពន្ធដើមឈ្មោះ [redacted]ហ៊ាប មានកូនប្រាំមួយនាក់ និង ប្រពន្ធចុងឈ្មោះ [redacted] ហឿន មានកូនប្រាំមួយនាក់។ ការដែលសពលោក [redacted] ហួរ បានរួមរស់ជាមួយនឹងប្រពន្ធចុងឈ្មោះ [redacted] ហឿន មានដីមួយកន្លែងទំហំ ១.២០៧៩ម² ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និង ពេលដែលសពលោក [redacted] ហួរ នៅរស់ នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០០ បានធ្វើលិខិតផ្ទេរសិទ្ធិដីអោយឈ្មោះ [redacted]សារ៉ាយ រួចហើយ នៅក្នុងឆ្នាំ ២០០៩ ឈ្មោះ [redacted] ហួរ បានទទួលមរណភាពទៅដោយពុំមានធ្វើមរតកសាសន៍អ្វីឡើយ។ នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ភាគីតំណាងអោយខាងប្រពន្ធ និង កូនដើម( [redacted] សុភា) និង តំណាងអោយខាងប្រពន្ធ និង កូនចុង [redacted]ជំនោរ) បានចុះកិច្ចព្រមព្រៀងគ្នាថា ឈប់ប្ដឹងផ្ដល់គ្នាចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងនេះតទៅ ស្រាប់តែនៅថ្ងៃ ១៥ ខែ កក្កដា ឆ្នាំ ២០១១ ចុងចម្លើយក៏បានដាក់ពាក្យបណ្ដឹងចូលមកតុលាការ ដើម្បីប្ដឹងសុំបែងចែកដីលំនៅឋានទំហំ ១២០៧៩ម២ ដោយសំអាងថា កាលលើកមុនចែកគ្នាតែដីស្រែទេ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៩"ខ" ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សំរេច :**

១-ប្រានចោលបណ្ដឹងទាមទារសុំអោយបែងចែកឡើងវិញនូវដីទំហំ ១២០៧៩ម² ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ របស់ដើមចោទឈ្មោះ [redacted] សុភា, [redacted]ផល្លា [redacted] ផល្លី [redacted] សុភាព, [redacted] វិណា, [redacted] សុផារី ពីសហចុងចម្លើយឈ្មោះ [redacted] ជំនោរ, [redacted] សារ៉ាយ, [redacted] ចំណាប់ [redacted] វតនា [redacted]តនៈ, [redacted] ធីតា, [redacted] ម៉ូនីកា, [redacted] ហ៊ីម និង [redacted] សុខា ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរតទៅ។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

៣-សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ ចំពោះមុខភាគីដើមចោទ និង ចុងចម្លើយឈ្មោះ [redacted] សារ៉ាយ, [redacted] រតនៈ, [redacted] ចំណាប់, [redacted] សុខា, កំបាំងមុខឈ្មោះ [redacted] ម៉ូ

នីកា, [redacted] ធីតា, [redacted] ជំនោរ, [redacted] រតនា និង [redacted] ហ៊ីម តែចាត់ទុកដូចជាចំពោះមុខ ។ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] សុភា ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ២០ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១២ គ្រប់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ៩១"ក្រ.V.អ" ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ សំរេច :**

១-លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០៩(ខ) ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២-លុបចោលលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០០ ។

៣-ដីទំនាស់ស្ថិតនៅភូមិទឹកថ្លា ឃុំទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យទំហំ ១២០១៦ម$^2$ តាមគំនូសប្លង់ដីទំនាស់ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ របស់ការិយាល័យសុរិយោដី និង ភូមិសាស្ត្រ ត្រូវបែងចែកជាពីរចំណែកស្មើគ្នា អោយទៅដើមចោទឈ្មោះ [redacted] សុភា, [redacted] ផល្លា, [redacted] ផល្លី, [redacted] សុភាព, [redacted] វីណា, [redacted] សុផារី មួយចំណែក និង មួយចំណែកទៀតអោយទៅឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ, [redacted] សុខា , [redacted] ជំនោរ, [redacted] ចំណាប់, [redacted] រតនា, [redacted] រតនះ, [redacted] ធីតា, [redacted] ម៉ូនីកា និង [redacted] ហ៊ីម ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ និង ចុងចម្លើយ ។

៥-សាលដីកានេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ បើកសិទ្ធិប្ដឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

*សាលដីកានេះ ត្រូវបានឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ, [redacted] រតនះ ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ៣០៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ គ្រប់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។*

**ខ-<u>អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី</u> :**

**លោក [redacted] សារ៉ាយ ធ្វើសេចក្ដីថ្លែងការណ៍ថា :** ដីនេះពីដំបូងជារបស់ម្ដាយខ្លួនបន្សល់ទុកតាំងពីឆ្នាំ ១៩៨៨ ។ទ្រព្យមរតករបស់ឪពុកខ្លួនបានធ្វើការបែងចែកអោយកូនៗទាំងសងខាងរួចរាល់អស់ហើយឯដីនេះជាទ្រព្យផ្ទាល់របស់ម្ដាយខ្លួនដែលឪពុកខ្លួនរក្សាទុកអោយម្ដាយខ្លួនដែលមានជម្ងឺ ។

**អ្នកស្រី [redacted] សុភា ធ្វើសេចក្ដីថ្លែងការណ៍ថា :** ចម្លើយនេះមិនពិតទេ ។ ឪពុកខ្លួនគ្រប់គ្រងទាំងប្រពន្ធដើម និង ប្រពន្ធចុង ដូច្នេះ ដីនេះជាមរតករបស់គ្រួសារទាំងសងខាង ព្រោះបានមកក្នុងពេលរស់នៅជុំទាំងសងខាង ។

**លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] សារាយ ធ្វើសេចក្ដីថ្លែងការណ៍**



Scanned with CamScanner

ថាៈ លោក [redacted] ហួរ ជាឪពុកបានប្រគល់សិទ្ធិកាន់កាប់ដីនេះអោយទៅលោក [redacted] សារាយ ដើម្បីបែងចែកឱ្យបងប្អូនខាងប្រពន្ធចុង ឯខាងប្រពន្ធដើមក៏មិនបានតវ៉ាដែរពេលឪពុកនៅរស់។ ហើយដីនេះលោក [redacted] សារាយក៏បានបែងចែកដីមរតកនេះអោយបង និង ប្អូន ១ចំណែកម្នាក់ និង បានធ្វើប័ណ្ណកម្មសិទ្ធិរៀង១ខ្លួនរួចហើយ។

តាមកិច្ចព្រមព្រៀងបែងចែកដីធ្លី ដើម្បីបញ្ឈប់ការប្តឹងផ្តល់គ្នានៅចំពោះមុខចៅសង្កាត់ គឺបានបែងចែកៈ

-ដីស្រែទំហំ ២០០ហិកតា អោយទៅឈ្មោះ [redacted] សុភា ដែលជាតំណាងអោយកូនដើម

-ដីស្រែទំហំ ៨៣ហិកតា អោយទៅឈ្មោះ [redacted] ជំនោរ ដែលជាតំណាងអោយកូនចុង

-ដីចំការ ៤៥ហិកតា ម្នាក់ តែចំណែកខាង [redacted] សុភា បានលក់អស់ហើយ

តែក្រោយមកឈ្មោះ [redacted] សុភា បែរជាប្តឹងទាមទារដីមរតកដែលលោក [redacted] ហួរ ផ្ទេរសិទ្ធិអោយទៅលោក [redacted] សារាយ ទៅវិញ។

សាលាដំបូងខេត្តបានពិនិត្យរួចហើយថា ស្នាមមេដៃផ្ទេរសិទ្ធិ គឺពិតជាស្នាមដៃលោក [redacted] ហួរ និងប្រពន្ធចុងប្រាកដមែន។ ហើយពាក្យសុំកាន់កាប់ដីធ្លី ២ហិកតា ដែលផ្ទេរអោយទៅលោក [redacted] សារាយ បែងចែកអោយបងប្អូន គឺមានតែឈ្មោះ [redacted] ហួរ និង ម្តាយចុងប៉ុណ្ណោះ។

**សំណូមពរ : សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលទាំងមូល។**

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] សុភា ធ្វើសេចក្តីថ្លែងការណ៍ថាៈ ម្តាយអ្នកស្រី អ៊ីវ សុភា ជាប្រពន្ធដើមមានកូន ៦នាក់ ក្រោយឆ្នាំ ៧៩ បានជួបលោក [redacted] ហួរ ជាប្តីវិញ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅខេត្តកំពង់ធំ ឯប្រពន្ធចុងត្រូវជាម្តាយរបស់ [redacted] សារាយ ពុំមានសំបុត្រអាពាហ៍ពិពាហ៍ទេ ។ កិច្ចព្រមព្រៀង គឺធ្វើតែលើដីស្រែ និង ដីចំការប៉ុណ្ណោះ។ តែចំពោះលិខិតផ្ទេរសិទ្ធិដែលលេចឡើងក្រោយពេលលោក [redacted] ហួរ ស្លាប់ អោយទៅលោក [redacted] សារាយ ដោយពុំមានការឯកភាពពីគ្រប់ភាគីទេ ។ សាក្សីក្នុងលិខិតប្រគល់សិទ្ធិគឺពុំទាន់មាននីតិភាពនៅឡើយ ម្យ៉ាងទៀតជាកូនរបស់ប្រពន្ធចុងទៀត និងពុំមានប្រថាប់ត្រានៅអាជ្ញាធរមូលដ្ឋាន និង មិនបានចុះបញ្ជីសុរិយោដីទៀត។ លោក [redacted] សារាយ មិនមែនជាកូនលោក [redacted] ហួរ ទេ គឺជាកូនប្តីមុនរបស់ប្រពន្ធចុង ហើយឈ្មោះ [redacted] សារាយ បានប្តូរយកត្រកូល [redacted] នៅពេលលោក [redacted] ហួរ ស្លាប់ហើយ ។

**សំណូមពរ : សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ**

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ និង [redacted] រតនះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ៥៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលុបចោលលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០០ និង បែងចែកដីទំនាស់ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទំហំ ១២.០១៦ម$^2$ ជាពីរចំណែកស្មើគ្នា អោយទៅដើមចោទឈ្មោះ [redacted] សុភា, [redacted] ផល្លា, [redacted] ផល្លី, [redacted] សុភាព, [redacted] វីណា, [redacted] សុផារី មួយចំណែក និង មួយចំណែកទៀតអោយទៅឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ, [redacted] សុខា, [redacted] ជំនោរ [redacted] ចំណាប់, [redacted] រតនះ, [redacted] ធីតា, [redacted] ម៉ូនីកា និង [redacted] ហ៊ីម ដោយអាងហេតុថា ដីទំនាស់ជាទ្រព្យរួមរបស់ [redacted] ហឿន និង [redacted] ហួរ ក៏ជាទ្រព្យរួមរបស់ [redacted] ហួរ និង [redacted] ហ៊ាប ដែរនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា :-

+នៅពេលនៅរស់ លោក [redacted] ហួរ បានផ្ទេរសិទ្ធិកាន់កាប់តាមរយៈលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០០ អោយទៅលោក [redacted] សារ៉ាយ រួចរាល់ហើយ ដែលតាមមាត្រា ១១៩៥ នៃក្រមរដ្ឋប្បវេណី ទ្រព្យសម្បត្តិនេះត្រូវធ្លាក់ទៅលើឈ្មោះ [redacted] សារ៉ាយ ដោយស្វ័យប្រវត្តិ ក្រោយពេលមរតកជនទទួលមរណភាពទៅ ដោយពុំអាចសើរើយកមកបែងចែកឡើងវិញបានឡើយ ។

+ភាគីដើមចោទ និង ភាគីចុងចម្លើយបានព្រមព្រៀងគ្នាឈប់ប្តឹងផ្តល់តាមលិខិតទម្រង់បែបបទនៃកិច្ចព្រមព្រៀងសំរុះសំរួល ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ។ ម្យ៉ាងទៀត នៅពេលចុះកិច្ចព្រមព្រៀងនេះសោតភាគីដើមចោទ ក៏ពុំបានទាមទារយកដីទំនាស់នោះមកបែងចែកគ្នាដែរ ទើបនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១០ ដើមចោទប្តឹងទាមទារបែងចែកដីកេរ្តិ៍ជាថ្មីឡើងវិញ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩១ក្រ.IVអ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងនឹងគតិច្បាប់ ។

### ហេតុដូចនេះ

### វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ របស់ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ និង [redacted] រតនះ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

475

Scanned with CamScanner

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៩១ក្រIVអ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៦៨ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ របស់តុលាការកំពូលទៅ សាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលដីកានេះជំនុំជំរះនាសវនាការជាសាធារណៈ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ និង ប្រកាស នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោកស្រី | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានឃើញ
ភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤
ប្រធាន
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner